ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:០៤ សរណន

# សារាចរណែនាំ

## ស្តីពីការត្រៀមទិដ្ឋានការទប់ទល់នឹងគ្រោះទឹកជំនន់

យោងតាមការពិនិត្យ សង្កេត តាមដានជាប់ជាប្រចាំលើស្ថានភាពអាកាសធាតុរបស់ក្រសួងធនធានទឹកនិងឧតុនិយមបានបង្ហាញថា ដោយសារឥទ្ធិពលរបស់ប្រព័ន្ធសម្ពាធទាប គួបផ្សំនឹងឥទ្ធិពលរបស់ព្យុះទី ១៤ ឈ្មោះ **កាហ្ស៊ីគី** ( KAJIKI ) និងឥទ្ធិពលនៃខ្យល់មូសុងនិរតីខ្លាំងបានបង្កឲ្យមានការធ្លាក់ភ្លៀងយ៉ាងតំហុកនៅក្នុងខេត្តមួយចំនួនរបស់ព្រះរាជាណាចក្រកម្ពុជា និងនៅតំបន់ផ្ទៃរងទឹកភ្លៀងរបស់ទន្លេមេគង្គ ក្នុងប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសឡាវ ។ ការធ្លាក់ភ្លៀងយ៉ាងតំហុកនេះ នឹងជម្រុញឲ្យទឹកទន្លេមេគង្គហក់ឡើងខ្ពស់ លឿន និងឈានទៅដល់កម្រិតមួយ ដែលបង្កឲ្យមានការលិចលង់នៅខេត្តមួយចំនួន ដែលស្ថិតនៅអមសងខាងទន្លេមេគង្គផ្នែកខាងលើ ។

យោងតាមការព្យាករកម្ពស់ទឹករបស់ក្រសួងធនធានទឹកនិងឧតុនិយមបានបង្ហាញថា ៖

- ស្ថានីយជលសាស្ត្រខេត្តស្ទឹងត្រែង ៖ នៅថ្ងៃទី ០៨ ខែកញ្ញា ទឹកអាចកើនឡើងដល់កម្ពស់ ១២,៣៥ ម៉ែត្រ ( កម្ពស់ប្រកាសអាសន្ន ១២,០០ ម៉ែត្រ )
- ស្ថានីយជលសាស្ត្រខេត្តក្រចេះ ៖ នៅថ្ងៃទី ០៩ ខែកញ្ញា ទឹកអាចកើនឡើងដល់កម្ពស់ ២៣,២០ ម៉ែត្រ ( កម្ពស់ប្រកាសអាសន្ន ២៣,០០ ម៉ែត្រ )
- ស្ថានីយជលសាស្ត្រខេត្តកំពង់ចាម ៖ នៅថ្ងៃទី ១០ ខែកញ្ញា ទឹកអាចកើនឡើងដល់កម្ពស់ ១៥,៧០ ម៉ែត្រ ( កម្ពស់ប្រកាសឲ្យប្រុងប្រយ័ត្ន ១៥,២០ ម៉ែត្រ )
- ស្ថានីយជលសាស្ត្របាសាក់ ចតុមុខ រាជធានីភ្នំពេញ ៖ នៅថ្ងៃទី ១១ ខែកញ្ញា ទឹកអាចកើនឡើងដល់កម្ពស់ ៩,៤៥ ម៉ែត្រ ( កម្ពស់ប្រកាសឲ្យប្រុងប្រយ័ត្ន ១០,៥០ ម៉ែត្រ )
- ដោយឡែក ចំពោះកម្ពស់ទឹកទន្លេមេគង្គក្រោម ទន្លេបាសាក់ ទន្លេសាប និងទឹកក្នុងបឹងទន្លេសាប ក៏ហក់ឡើងទន្ទឹមគ្នាផងដែរ ។
- ទន្ទឹមនោះ ទឹកនៅតាមបណ្តាស្ទឹងមួយចំនួន ក៏បាន និងកំពុងកើនឡើងជាបន្តបន្ទាប់ផងដែរ ។

យោងលើស្ថានភាពអាកាសធាតុ និងស្ថានភាពកម្ពស់ទឹក ដូចបានបញ្ជាក់ជូនខាងលើ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីទាំងអស់ ត្រូវចាត់វិធានការចាំបាច់នានា ត្រៀមទប់ទល់នឹងគ្រោះទឹកជំនន់ កាត់បន្ថយឲ្យបានជាអតិបរមានូវការលំបាក និងការប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ ។

ថ្ងៃ ពុធ ៦ កើត ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ